ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៧៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែប្រែដែនជម្រកសត្វព្រៃភ្នំត្នោត-ភ្នំពក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- អនុក្រឹត្យលេខ១៤៣ អនក្រ.បក ចុះថ្ងៃទី៣១ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការបង្កើតដែនជម្រកសត្វព្រៃភ្នំត្នោត-ភ្នំពក

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .-**

ត្រូវបានកែប្រែដែនជម្រកសត្វព្រៃភ្នំត្នោត-ភ្នំពក ពីផ្ទៃដីទំហំ៤២ ០៩៧(បួនម៉ឺនពីរពាន់កៅសិបប្រាំពីរ) ហិកតា មកផ្ទៃដីទំហំ៥១ ៧៣០(ប្រាំម៉ឺនមួយពាន់ប្រាំពីររយសាបសិប)ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តសៀមរាប និងខេត្តព្រះវិហារ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១និងនិយាមកា(តាមប្រព័ន្ធកូអរដោនេ Project UTM Zone 48N Datum WGS 1984) ភ្ជាប់ក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

ផ្ទៃដីដែនជម្រកសត្វព្រៃភ្នំត្នោត-ភ្នំពកខាងលើនេះ បានមកពីការបូកបញ្ចូលផ្ទៃដីទំហំ៤២ ០៩៧(បួនម៉ឺនពីរពាន់កៅសិបប្រាំពីរ)ហិកតា ដូចមានចែងក្នុងអនុក្រឹត្យលេខ១៤៣ អនក្រ.បក ចុះថ្ងៃទី៣១ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការបង្កើតដែនជម្រកសត្វព្រៃភ្នំត្នោត-ភ្នំពក និងផ្នែកខ្លះនៃរបៀងអភិរក្សជីវៈចម្រុះឧត្តរ ដែលមានផ្ទៃដីទំហំ ៩ ៦៣៣(ប្រាំបួនពាន់ប្រាំមួយរយសាមសិបបី)ហិកតា ដូចមានចែងក្នុងអនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ធានាឱ្យមានការថែទាំទីជម្រកសត្វព្រៃនិងប្រព័ន្ធអេកូឡូស៊ី ព្រមទាំងធានាឱ្យមានការបំពេញលក្ខខណ្ឌចាំបាច់សម្រាប់ប្រភេទណាមួយនៃសត្វ រុក្ខជាតិ និងជីវៈចម្រុះ
- រក្សាលំនឹងបរិស្ថាន និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុនិងហានិភ័យគ្រោះមហន្តរាយធម្មជាតិ
- ធានាការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយសនិទានភាពនិងនិរន្តរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាសាធារណជនក្នុងការចូលរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិក្នុងតំបន់។

**មាត្រា៣ .-**

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ កែប្រែ និងគ្រប់គ្រងតំបន់ដែនជម្រកសត្វព្រៃភ្នំត្នោត-ភ្នំពក ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលខេត្តសៀមរាប និងរដ្ឋបាលខេត្តព្រះវិហារ ដើម្បីធានាដល់ការគ្រប់គ្រងបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការរស់នៅដោយចីរភាព ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤ .-**

លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការកំណត់តំបន់សហគមន៍ តំបន់ប្រើប្រាស់ដោយចីរភាព ការវិនិយោគ ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លី ដែលអនុលោមតាមអនុក្រឹត្យស្តីពីការបង្កើតដែនជម្រកសត្វព្រៃភ្នំត្នោត-ភ្នំពក អនុក្រឹត្យស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៥ .-**

អនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្ដីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តសៀមរាប និង អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៥ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



Map Coordinate System:
Units: meters
System Projection: UTM, Zone 48 N
Datum: WGS 1984
1:150,000
10 km
Google Earth

**ឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ១៧៦ អនក្រ.បក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៣**
**ចំណុចនិយាមការនៃផែនទីដែនជម្រកសត្វព្រៃភ្នំត្នោត-ភ្នំពក**

| ID | X | Y | ID | X | Y | ID | X | Y |
|---|---|---|---|---|---|---|---|---|
| 1 | 469967 | 1483244 | 31 | 442750 | 1488407 | 62 | 446761 | 1506492 |
| 2 | 470685 | 1481855 | 32 | 442254 | 1488632 | 63 | 447313 | 1507120 |
| 3 | 466743 | 1481751 | 33 | 442208 | 1489797 | 64 | 447554 | 1506794 |
| 4 | 463297 | 1481671 | 34 | 442724 | 1491186 | 65 | 448053 | 1506374 |
| 5 | 459385 | 1483028 | 35 | 442194 | 1491642 | 66 | 448590 | 1506877 |
| 6 | 455075 | 1482112 | 36 | 442016 | 1490630 | 67 | 449125 | 1506675 |
| 7 | 452540 | 1483149 | 37 | 441282 | 1491179 | 68 | 449213 | 1506104 |
| 8 | 449973 | 1483814 | 38 | 440283 | 1491728 | 69 | 449705 | 1506520 |
| 9 | 449965 | 1485644 | 39 | 440825 | 1492608 | 70 | 450247 | 1506722 |
| 10 | 450016 | 1487169 | 40 | 441387 | 1493097 | 71 | 450511 | 1507368 |
| 11 | 448473 | 1488754 | 41 | 441517 | 1494601 | 72 | 450925 | 1507905 |
| 12 | 446902 | 1488749 | 42 | 440905 | 1495245 | 73 | 451529 | 1506991 |
| 13 | 446227 | 1489122 | 43 | 440790 | 1496715 | 74 | 450258 | 1503753 |
| 14 | 446021 | 1488042 | 44 | 441706 | 1498326 | 75 | 450067 | 1502047 |
| 15 | 445132 | 1486923 | 45 | 441830 | 1498578 | 76 | 449885 | 1500535 |
| 16 | 445203 | 1488074 | 46 | 442016 | 1499082 | 77 | 451911 | 1498929 |
| 17 | 445455 | 1489897 | 47 | 444115 | 1500315 | 78 | 453813 | 1499414 |
| 18 | 445512 | 1491275 | 48 | 442131 | 1500346 | 79 | 455289 | 1499821 |
| 19 | 445705 | 1491978 | 49 | 441846 | 1501352 | 80 | 455931 | 1498993 |
| 20 | 446671 | 1492867 | 50 | 442075 | 1502683 | 81 | 459907 | 1500611 |
| 21 | 448144 | 1493325 | 51 | 441078 | 1502873 | 82 | 460893 | 1498447 |
| 22 | 446293 | 1493986 | 52 | 441685 | 1504365 | 83 | 461556 | 1500845 |
| 23 | 444909 | 1493885 | 53 | 442546 | 1504805 | 84 | 464998 | 1499387 |
| 24 | 443714 | 1494930 | 54 | 443291 | 1505531 | 85 | 468209 | 1498053 |
| 25 | 442589 | 1493772 | 55 | 442509 | 1505975 | 86 | 471235 | 1496794 |
| 26 | 443267 | 1492896 | 56 | 443065 | 1506495 | 87 | 474032 | 1495636 |
| 27 | 443822 | 1492131 | 57 | 443948 | 1506455 | 88 | 474154 | 1493299 |
| 28 | 443669 | 1491238 | 58 | 444415 | 1505955 | 89 | 473048 | 1491257 |
| 29 | 443319 | 1490094 | 59 | 445247 | 1505998 | 90 | 473929 | 1488155 |
| 30 | 443220 | 1489162 | 60 | 445980 | 1505535 | 91 | 476764 | 1483350 |
| | | | 61 | 446245 | 1506315 | 92 | 473908 | 1485319 |